**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តស្វាយរៀង

**សាលាដំបូងខេត្តស្វាយរៀង**

សំណុំរឿងរដ្ឋប្បវេណី

លេខ:៥២ ចុះថ្ងៃទី០៨-៤-២០១៩

សាលក្រមរដ្ឋប្បវេណី

លេខ:៥៥(ក)ចុះថ្ងៃទី២៦-៦-២០១៩

-កាលបរិច្ឆេទបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី២៦-៦-២០១៩

-កាលបរិច្ឆេទនៃការប្រកាសសាលក្រម ថ្ងៃទី២៦-៦-២០១៩

## សាលក្រមរដ្ឋប្បវេណី

-ចៅក្រមជំនុំជម្រះ លោក[redacted]ប្រធានសាលាដំបូងខេត្តស្វាយរៀង

-ក្រឡាបញ្ជីសវនាការ កញ្ញា[redacted]ក្រឡាបញ្ជីសាលាដំបូងខេត្តស្វាយរៀង

សំណុំរឿងរដ្ឋប្បវេណី រវាង៖

**-ដើមចោទ៖** [redacted] មានអាសយដ្ឋាននៅអគារលេខ [redacted] តំណាងដោយ លោក[redacted]រដ្ឋា។ មានមេធាវីតំណាងដោយអាណត្តិ គឺលោក[redacted]។

**-សហចុងចម្លើយ:**

១.ឈ្មោះ[redacted] **ណារិន** ភេទប្រុស អាយុ៦១ឆ្នាំ មុខរបរ មន្ត្រីនគរបាលចូលនិវត្តន៍ និងប្រពន្ធឈ្មោះ [redacted] ផល្លី អាយុ៥៧ឆ្នាំ មុខរបរ មេផ្ទះ អាសយដ្ឋាននៅ[redacted]។

២.ឈ្មោះ[redacted] **កល្យាណ** ភេទប្រុស អាយុ៣៦ឆ្នាំ មុខរបរ លក់ដូរ និងប្រពន្ធឈ្មោះ[redacted] ទេវី អាយុ៣៣ឆ្នាំ មុខរបរ លក់ដូរ អាសយដ្ឋាននៅ[redacted]។

មេធាវីតំណាងដោយអាណត្តិរបស់សហចុងចម្លើយ គ្មាន។

## អង្គហេតុ និងចំណុចវិវាទ:

**ក.ដើមចោទប្តឹងសុំតុលាការចេញសាលក្រមសម្រេចឲ្យសហចុងចម្លើយ:**

១-រួមគ្នាសងប្រាក់ដើមនៅជំពាក់សរុបចំនួន:៣៩ ៥៨៣,៤០ដុល្លារអាមេរិក។

២-បង់ការប្រាក់តាមកិច្ចសន្យាអត្រា១២%ក្នុង១ឆ្នាំលើប្រាក់ដើមនៅជំពាក់ចំនួន៣៩ ៥៨៣,៤០ដុល្លារអាមេរិក គិតពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ ដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់។

៣-បង់ការប្រាក់ពិន័យក្នុងអត្រាស្មើនឹង២ដងនៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យា គិតពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទូទាត់សងចប់សព្វគ្រប់។

៤-បង់សេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តចំនួន ៥០០០ដុល្លារអាមេរិក។

៥-សាលក្រមស្នើសុំប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នលើចំណុចសងប្រាក់ដើម បង់ការប្រាក់ធម្មតា និងបង់ប្រាក់ពិន័យ(ដូចមាននៅចំណុចទី១,២ និងទី៣នៃកម្មវត្ថុបណ្តឹង)។

៦-ឲ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

## អង្គហេតុជាមូលហេតុ:



Scanned with CamScanner

-នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ សហចុងចម្លើយបានចុះកិច្ចសន្យានិងខ្ចីចងការប្រាក់ពី[redacted](ដើមចោទ)នូវប្រាក់ដើមចំនួន៥០ ០០០ដុល្លារអាមេរិក យល់ព្រមបង់ការប្រាក់អត្រា១២%ក្នុង១ឆ្នាំលើប្រាក់ដើម បង់ការប្រាក់ពិន័យអត្រាស្មើនឹង២ដងនៃការប្រាក់ធម្មតាក្នុង១ឆ្នាំលើប្រាក់ដើមនៅជំពាក់ ខ្ចីរយៈពេល៦០ខែ និងកំណត់របៀបនៃការសងប្រាក់មកធនាគារវិញគឺ បង់រំលោះនូវប្រាក់ដើមថេរ រួមបង់ការប្រាក់ថយចុះរៀងរាល់ខែ គិតចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ និងកំណត់នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ជាថ្ងៃសងប្រាក់ដើម និងការប្រាក់ផ្តាច់។ ដោយភាគីសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច គឺពុំបានបង់សងប្រាក់ដើម និងការប្រាក់តាមកាលកំណត់នៅក្នុងកាលវិភាគបង់ប្រាក់ប្រចាំខែនីមួយៗតាមកិច្ចសន្យា ទើបភាគីដើមចោទ គឺ[redacted]ប្តឹងរឿងនេះមកតុលាការ។

**ខ-ការអះអាងរបស់គូភាគី:**

**ខ.១-ការអះអាងរបស់ដើមចោទ៖**

-លោក[redacted]ជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីដើមចោទគឺធនាគារ[redacted]បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀម ក៏ដូចជានៅក្នុងនីតិវិធីនៃការធ្វើការទាញហេតុផលដោយផ្ទាល់មាត់នេះថា: នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ សហចុងចម្លើយឈ្មោះ[redacted] **ណារិន** ប្រពន្ធឈ្មោះ[redacted] **ផល្លី** និងអ្នករួមខ្ចីឈ្មោះ[redacted] **កល្យាណ** ប្រពន្ធឈ្មោះ[redacted] **ទេវី** បានចុះកិច្ចសន្យាខ្ចីចងការប្រាក់ពីធនាគា[redacted](ដើមចោទ)នូវប្រាក់ដើមចំនួន៥០ ០០០ដុល្លារអាមេរិក យល់ព្រមបង់ការប្រាក់អត្រា១២%ក្នុង១ឆ្នាំលើប្រាក់ដើម និងបង់ការប្រាក់ពិន័យអត្រាស្មើនឹង២ដងនៃការប្រាក់ធម្មតាលើប្រាក់ដើមនៅជំពាក់ ខ្ចីរយៈពេល៦០ខែ និងបានកំណត់របៀបនៃការសងប្រាក់មកធនាគារវិញគឺ បង់រំលោះនូវប្រាក់ដើមថេរ រួមបង់ការប្រាក់ថយចុះរៀងរាល់ខែ គិតចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ និងកំណត់នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ជាថ្ងៃសងប្រាក់ដើម និងការប្រាក់ផ្តាច់។ ប៉ុន្តែរយៈពេលជាច្រើនខែមកនេះ សហចុងចម្លើយខកខានពុំបានសងប្រាក់ដើម និងការប្រាក់តាមកិច្ចសន្យាដូចមានកំណត់ក្នុងតារាងបង់ប្រាក់ប្រចាំខែនោះឡើយ គិតមកទល់ពេលនេះសហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន៣៩ ៥៨៣,៤០ដុល្លារអាមេរិក រួមការប្រាក់ធម្មតា និងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨រហូតមក។

**ខ.២-ការអះអាងរបស់សហចុងចម្លើយ:**

១-ឈ្មោះ[redacted] **ណារិន** (សហចុងចម្លើយ)បានធ្វើសេចក្តីថ្លែងការណ៍តបទាំងនៅក្នុងនីតិវិធីត្រៀម ក៏ដូចជានៅក្នុងនីតិវិធីនៃការធ្វើការទាញហេតុផលដោយផ្ទាល់មាត់នេះថា: ប្តីប្រពន្ធខ្លួនពិតជាបានចុះកិច្ចសន្យា និងខ្ចីចងការប្រាក់[redacted]ដើមចោទ)នូវប្រាក់ដើមចំនួន៥០ ០០០ដុល្លារអាមរិកកាលពីថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ដោយខ្ចីរយៈពេល៦០ខែ យល់ព្រមបង់ការប្រាក់អត្រា១២%ក្នុង១ឆ្នាំលើប្រាក់ដើម បង់ប្រាក់ពិន័យក្នុងអត្រាស្មើ២ដងនៃការប្រាក់ធម្មតាក្នុង១ឆ្នាំលើប្រាក់ដើមនៅជំពាក់ ហើយរយៈពេលកន្លងមកខ្លួនពិតជាបានខកខានមិនបានបង់ប្រាក់ទៅឲ្យដើមចោទ ទាំងដើម និងការ(បង់រំលោះ) ដូចភាគីដើមចោទបានប្តឹងទាមទារ និងអះអាង



Scanned with CamScanner

នោះមែន។ នៅក្នុងរឿងនេះ ខ្លួនសុំសន្យាសងទៅភាគីដើមចោទវិញ គឺសុំសងតែប្រាក់ដើម និងការប្រាក់ធម្មតាដែលនៅជំពាក់ ដោយសុំសងជាខែគឺ១ខែចំនួន៣០០ដុល្លារអាមេរិក រហូតដល់គ្រប់ចំនួន ឯចំពោះការប្រាក់ពិន័យ សេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងជម្ងឺចិត្តដែលភាគីដើមចោទទាមទារពីខ្លួននោះ ខ្លួនពុំមានលទ្ធភាពបង់ឡើយ ដោយឡែកចំពោះសាលក្រមស្នើសុំឱ្យប្រកាសអនុវត្តជាបណ្ដោះអាសន្ននោះ ខ្លួនសុំច្រានចោល។

២.ឈ្មោះ[redacted] **កល្យាណ** (សហចុងចម្លើយ)បានធ្វើសេចក្ដីថ្លែងការណ៍តបនឹងភាគីដើមចោទនៅក្នុងនីតិវិធីនៃការធ្វើការទាញហេតុផលដោយផ្ទាល់មាត់នេះថា ខ្លួន និងប្រពន្ធខ្លួនពិតជាបានចូលរួមខ្ចីចងការប្រាក់ពីភាគីដើមចោទ គឺ[redacted]សាខាស្វាយរៀងជាមួយឪពុក និងម្ដាយខ្លួនពិតមែន។ ក្នុងរឿងធនាគារ (ដើមចោទ)ប្ដឹងទាមទារប្រាក់ពីប្ដីប្រពន្ធខ្លួន និងឪពុកម្ដាយខ្លួននោះ ខ្លួនរក្សាជំហរសងដូចដែលឪពុកខ្លួនបានលើកឡើងខាងលើ។

## គ.ចំណុចវិវាទ:

### គ.១-ចំណុចគ្មានវិវាទ:

-ឈ្មោះ[redacted] **ណារិន** (ឪពុក)និងឈ្មោះ[redacted] **កល្យាណ**(ជាកូន)និងជាភាគីសហចុងចម្លើយបានទទួលស្គាល់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ភាគីដើមចោទទាំងស្រុង។

### គ.២-ចំណុចវិវាទ:

-សហចុងចម្លើយទទួលស្គាល់អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ ប៉ុន្តែពុំព្រមសងប្រាក់ទៅឱ្យដើមចោទវិញតាមការទាមទារ។

## ឃ-អំពីភស្តុតាង:

### ឃ.១-.ភស្តុតាងភាគីដើមចោទ:

១-របាយការណ៍បំណុល ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩(ថតចម្លង) ចំនួន០១ច្បាប់។

២-តារាងបង់រំលស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩(ថតចម្លង) ចំនួន០១ច្បាប់។

៣-លិខិតកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧(ថតចម្លង) ចំនួន០១ច្បាប់។

៤-ឧបសម្ព័ន្ធនៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧(ថតចម្លង) ចំនួន០១ច្បាប់។

៥-លិខិតកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧(ថតចម្លង)ចំនួន០១ច្បាប់។

៦-លិខិតកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧(ថតចម្លង) ចំនួន០១ច្បាប់។

៧-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ[redacted] ណារិន,ឈ្មោះ[redacted] ផល្លី,ឈ្មោះ[redacted] កល្យាណនិងឈ្មោះ[redacted] ទេវី (ថតចម្លង) ចំនួន ០៤ច្បាប់។

### ឃ.២-ភស្តុតាងរបស់សហចុងចម្លើយ:(គ្មាន)

## សំអាងហេតុ:

-នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ សហចុងចម្លើយបានចុះកិច្ចសន្យា និងខ្ចីចងការប្រាក់ពី[redacted]សាខាស្វាយរៀង(ដើមចោទ)នូវប្រាក់ដើមចំនួន៥០ ០០០ដុល្លារអាមេរិក យល់ព្រមបង់ការប្រាក់អត្រា១២%ក្នុង១ឆ្នាំលើប្រាក់ដើម បង់ការប្រាក់ពិន័យអត្រាស្មើនឹង២ដងនៃការប្រាក់ធម្មតាក្នុង១ឆ្នាំលើប្រាក់ដើមនៅ



Scanned with CamScanner

ជំពាក់ខ្ចីរយៈពេល៦០ខែ និងកំណត់របៀបសងប្រាក់មកធនាគារវិញគឺ បង់រំលោះនូវប្រាក់ដើមថេរ រួមបង់ការប្រាក់ថយចុះរៀងរាល់ខែ គិតចាប់ពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ រហូតដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២៣ និងកំណត់នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ជាថ្ងៃសងប្រាក់ដើម និងការប្រាក់ផ្តាច់។ ដោយភាគីសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច គឺពុំបានបង់សងប្រាក់ដើម និងការប្រាក់តាមកាលកំណត់នៅក្នុងកាលវិភាគបង់ប្រាក់ប្រចាំខែនីមួយៗតាមកិច្ចសន្យា ទើបភាគីដើមចោទប្តឹងរឿងនេះមកតុលាការនោះ តុលាការគប្បីទទួលមកពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

សហចុងចម្លើយឈ្មោះ[redacted] **ណារិន** ប្រពន្ធឈ្មោះ[redacted] **ផល្លី** និងកូនឈ្មោះ[redacted] **កល្យាណ** ប្រពន្ធឈ្មោះ[redacted] **ទេវី** ពិតជាបានបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយ[redacted]សាខាស្វាយរៀង តាមលិខិតកិច្ចសន្យាចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧នោះពិតមែន មកទល់ពេលនេះសហចុងចម្លើយពុំបានអនុវត្តកាតព្វកិច្ច ពោលគឺពុំបានសងប្រាក់ដើម ការប្រាក់តាមការកំណត់ក្នុងកិច្ចសន្យាដូចមានក្នុងតារាងបង់ប្រាក់រំលោះ (ប្រាក់ដើម និងការប្រាក់)ដូចដែលភាគីដើមចោទគឺ[redacted]ប្តឹងទាមទារ និងអះអាងនោះមែន។

តាំងពីខ្ចីចងការប្រាក់មក សហចុងចម្លើយបានសងប្រាក់ដើម និងការប្រាក់ទៅឱ្យដើមចោទវិញតាមរបៀបបង់ប្រាក់ដើមថេរ និងការប្រាក់ថយចុះ ទៅតាមខែនីមួយៗដូចមានក្នុងតារាងបង់រំលោះប្រាក់ដើម និងការប្រាក់ភ្ជាប់ជាមួយនោះ ឃើញថា សហចុងចម្លើយបានបង់ប្រាក់នេះចាប់ពីខែដំបូង មកដល់ត្រឹមថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៨ប៉ុណ្ណោះ នៅខែបន្តបន្ទាប់ គឺចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ដល់បច្ចុប្បន្ន សហចុងចម្លើយខកខានពុំបានបង់សងប្រាក់នេះទៅដើមចោទទាំងដើម និងការ ដូចដែលភាគីដើមចោទប្តឹងទាមទារ និងអះអាងពិតមែន។

សហចុងចម្លើយឈ្មោះ[redacted] **ណារិន** បានអះអាងថា ខ្លួន និងប្រពន្ធខ្លួនជាអ្នករួមគ្នាខ្ចីចងការប្រាក់ពី[redacted](ដើមចោទ) ឯកូនខ្លួនឈ្មោះ[redacted]**កល្យាណ** និងប្រពន្ធឈ្មោះ[redacted] **ទេវី** ពុំមែនអ្នកខ្ចីទេ គ្រាន់ធ្វើជាសាក្សីឱ្យខ្លួនប៉ុណ្ណោះ និងថាខ្លួន និងប្រពន្ធខ្លួនជាអ្នកទទួលខុសត្រូវសង ពុំឱ្យពាក់ព័ន្ធដល់កូនទេ ប៉ុន្តែឈ្មោះ[redacted]**កល្យាណ** បានចូលរួមនៅក្នុងនីតិវិធីនៃការធ្វើការទាញហេតុផលដោយផ្ទាល់មាត់នេះថា ប្តីប្រពន្ធខ្លួនបានរួមគ្នាខ្ចីប្រាក់ពីធនាគារជាមួយឪពុកម្តាយខ្លួនពិតមែននោះ បញ្ហានេះតុលាការធ្វើការពិចារណា ដោយផ្អែកលើមូលដ្ឋាននៃលិខិតកិច្ចសន្យាខ្ចីបរិភោគដែលគូភាគីបានបង្កើតនោះតាមច្បាប់។

ភាគីដើមចោទមានលោក[redacted] **រដ្ឋា** ជាតំណាង[redacted] ផ្អែកតាមបណ្តឹងរបស់លោកក៏ដូចជាសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់របស់លោកមេធាវី[redacted] ជាមេធាវីតំណាងដោយអាណត្តិភាគីដើមចោទ នៅតែប្តឹងទាមទារប្រាក់ដើមនៅជំពាក់ចំនួន៣៩ ៥៨៣,៤០ដុល្លារអាមេរិក និងការប្រាក់អត្រា១២% ក្នុង១ឆ្នាំលើប្រាក់ដើមនៅជំពាក់ផ្អែកតាមកិច្ចសន្យានោះ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការទទួលស្គាល់ការទាមទារនេះតាមច្បាប់។

ភាគីដើមចោទក្រៅពីទាមទារប្រាក់ដើម និងការប្រាក់តាមកិច្ចសន្យា នៅទាមទារប្រាក់ពិន័យអត្រាស្មើ២ដងនៃអត្រាការប្រាក់ធម្មតាក្នុង១ឆ្នាំលើប្រាក់ដើមជំពាក់ តាមកិច្ចសន្យាគិតចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨



Scanned with CamScanner

ដល់ថ្ងៃទូទាត់សងប្រាក់ដើមចប់សព្វ ព្រមទាំងទាមទារថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជម្ងឺចិត្តទៀតនោះ តុលាការទទួលស្គាល់ការទាមទារនេះ និងសម្រេចតាមច្បាប់។

ភាគីដើមចោទស្នើសុំតុលាការប្រកាសសាលក្រមឱ្យអនុវត្តជាបណ្តោះអាសន្នលើចំណុចនៃការសងប្រាក់ដើម បង់ការប្រាក់ និងបង់ការប្រាក់ពិន័យ។ ការទាមទារនេះ តុលាការទទួលស្គាល់ និងសម្រេចតាមច្បាប់។

-ផ្អែកតាមបញ្ញត្តិនៃមាត្រា៥៧៨.៥៧៩.៥៨៣.៥៨៤.៥៨៥ និងមាត្រា៣៩៨ក្រមរដ្ឋប្បវេណី,បញ្ញត្តិនៃមាត្រា១៧ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, មាត្រា១៩៦នៃក្រមនីតិវិធីរដ្ឋប្បវេណី និងប្រកាសលេខ:១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១របស់ក្រសួងយុត្តិធម៌។

-ផ្អែកតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់:

១-ឱ្យសហចុងចម្លើយឈ្មោះ[redacted] ណារិន,ប្រពន្ធឈ្មោះ[redacted] ផល្លី និងឈ្មោះ[redacted] កល្យាណ, ប្រពន្ធឈ្មោះ[redacted] ទេវី រួមគ្នាសងប្រាក់ទៅ[redacted] ដែលមានលោក[redacted] រដ្ឋា ជាតំណាង និងមានលោក[redacted] ជាមេធាវីតំណាងដោយអាណត្តិនោះគឺ:

ក-ប្រាក់ដើមចំនួន៣៩ ៥៨៣,៤០ដុល្លារអាមេរិក។

ខ-បង់ការប្រាក់អត្រា១២%ក្នុង១ឆ្នាំលើប្រាក់ដើមនៅជំពាក់ចំនួន៣៩ ៥៨៣,៤០ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ រហូតដល់សងប្រាក់ដើមគ្រប់ចំនួន។

គ-បង់ការប្រាក់ពិន័យអត្រាស្មើនឹង២ដងនៃអត្រាការប្រាក់ តាមកិច្ចសន្យាខ្ចីបរិភោគលេខ:០៧៧/២០១៧ ឥ.១ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ គិតចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ ដល់ថ្ងៃទូទាត់ចប់សព្វគ្រប់។

២-ឱ្យសហចុងចម្លើយ បង់សំណងការខូចខាត និងជម្ងឺចិត្តទៅឱ្យដើមចោទចំនួន៥ ០០០ ០០០រៀល។

៣-សាលក្រមនេះ អាចអនុវត្តជាបណ្តោះអាសន្នបានលើចំណុចទី១(ក.ខ.គ)ខាងលើ។

៤-សហចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី។

សាលក្រមនេះបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈចំពោះមុខភាគីដើមចោទ និងសហចុងចម្លើយនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩។

-បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមបញ្ញត្តិច្បាប់។

**ចៅក្រមជំនុំជម្រះ:**

**ហត្ថលេខា និងត្រា**[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃពុធ ៩កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ស្វាយរៀង,ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ:**

[redacted]



Scanned with CamScanner